ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

តុលាការរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណីលេខ ១០១០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។
- សាលក្រមលេខ៖ ១៤២ "ម" ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

(ដោយមិនឆ្លងកាត់ការទាញហេតុដោយផ្ទាល់មាត់)

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ ៖** ក្រុមហ៊ុន [redacted] ដោយមានអ្នកតំណាងស្របច្បាប់ ឈ្មោះ [redacted] HUA ជាប្រធានក្រុមប្រឹក្សាភិបាល។

**អ្នកតំណាងដោយអាណត្តិ**

- លោកមេធាវី [redacted] មានការិយាល័យ [redacted]
- លោកមេធាវី [redacted]

**ចុងចម្លើយ៖** ក្រុមហ៊ុន [redacted] មានទីស្នាក់ការ [redacted] ដោយមានអ្នកតំណាងឈ្មោះ [redacted] LEPING ជាប្រធានក្រុមប្រឹក្សា និងឈ្មោះ [redacted] LANFA ជានាយកប្រតិបត្តិ។

**អ្នកតំណាងដោយអាណត្តិ**

លោកមេធាវី [redacted] ស្ថិតនៅអគារលេខ [redacted]។


អាសយដ្ឋាន: អាគារលេខ ៦៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
ទូរសារ- ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59
Scanned with CamScanner

## អង្គហេតុ និងការទាមទារ

### ក. ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ

១. សុំឱ្យចុងចម្លើយបន្តអនុវត្តកិច្ចសន្យាក្របខណ្ឌនៃការផ្គត់ផ្គង់បណ្តាញតភ្ជាប់ខ្សែកាបអុបទិក លេខ៖ SINGMENG-CFOCN 2016071501 (“កិច្ចសន្យាផ្គត់ផ្គង់បណ្តាញតភ្ជាប់ខ្សែកាប អុបទិក” [redacted]”) រួមមានដូចជា៖ ការផ្តល់សេវាផ្គត់ផ្គង់បណ្តាញតភ្ជាប់ខ្សែកាបអុបទិក សេវាកម្មថែទាំ និងសេវាកម្មតភ្ជាប់ឡើងវិញជូនអតិថិជនដែលត្រូវបានកាត់ផ្តាច់កន្លងមក ដោយហាមមិនឱ្យចុងចម្លើយកាត់ផ្តាច់ ឬ បញ្ឈប់ការផ្តល់សេវាផ្គត់ផ្គង់បណ្តាញរបស់ដើមចោទ លុះត្រាមានការរំលាយកិច្ចសន្យា ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាផ្គត់ផ្គង់បណ្តាញតភ្ជាប់ខ្សែកាបអុបទិក ឬ ក្នុងករណីដើមចោទមិនអនុវត្តតាមកាតព្វកិច្ចណាមួយដែលមានកំណត់ក្នុងកំណត់ហេតុផ្សះផ្សាវិវាទលើបញ្ហា [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

២. បង្គាប់ឱ្យចុងចម្លើយផ្តល់ឯកសាររបាយការណ៍ និងវិក្កយបត្រ គិតចាប់ពីខែមករា ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២១ មកឱ្យដើមចោទ ដែលមានតម្លៃប្រហែល ២៣៧.៩៦០ (ពីររយសាមសិបប្រាំពីរពាន់ប្រាំបួនរយហុកសិប) ដុល្លារអាមេរិក ស្របតាមកំណត់ហេតុប្រជុំស្តីពីកិច្ចសម្របសម្រួលផ្សះផ្សាវិវាទលើបញ្ហា [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់និយ័តករទូរគមនាគមន៍កម្ពុជា។

៣. សុំឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

### ខ. ការសង្ខេបរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាបង្កើតនូវកិច្ចសន្យាស្តីពីការផ្គត់ផ្គង់បណ្តាញ [redacted] លេខ៖ SINGMENG CFOCN 201607150 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦។ លុះក្រោយមកដើមចោទជំពាក់បំណុលថ្លៃផ្គត់ផ្គង់បណ្តាញនេះ និងត្រូវបាន **និយ័តករទូរគមនាគមន៍កម្ពុជា** ធ្វើការសម្របសម្រួលផ្សះផ្សាតាមពាក្យប្តឹងរបស់ចុងចម្លើយ។ ជាលទ្ធផល ដើមចោទមានកាតព្វកិច្ចសងបំណុលមកចុងចម្លើយ ដូចបានបញ្ជាក់ក្នុងកំណត់ហេតុផ្សះផ្សាលើបញ្ហា NETWORK ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។ តែដើមចោទនៅតែមិនព្រមទូទាត់សងបំណុលតាមកំណត់ហេតុនោះឡើយ។ ចំពោះករណីនេះ ចុងចម្លើយបានដាក់ពាក្យប្តឹងទៅ **និយ័តករទូរគមនាគមន៍កម្ពុជា** ដើម្បីធ្វើការសម្របសម្រួលជាបន្តបន្ទាប់ ដោយទាមទារសុំឱ្យដើមចោទទូទាត់សងបំណុល។ ដោយសារតែដើមចោទមិនបានទូទាត់សងបំណុល និងដោយសារតែមានសំណើរបស់ចុងចម្លើយ និយ័តករទូរគមនាគមន៍កម្ពុជាបានឯកភាព និងអនុញ្ញាតឱ្យបញ្ឈប់ការផ្តល់សេវាអ៊ីនធើណេត ដល់អតិថិជនរបស់ដើមចោទ ក្នុងករណីមិនព្រមទូទាត់បំណុល ដូចបានបញ្ជាក់ក្នុងលិខិតលេខ ០១៥៤ ន.ទ.ក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១។ ជាចុងក្រោយ ចុងចម្លើយបានចេញសេចក្តីជូនដំណឹង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ដោយក្នុងនោះ ចុងចម្លើយបានប្រកាសជាសាធារណៈដល់អតិថិជនទាំងអស់ ដែលប្រើប្រាស់អ៊ីនធើណេតរបស់ក្រុមហ៊ុនដើមចោទឱ្យធ្វើការជ្រើសរើសក្រុមហ៊ុន ISP ថ្មីណាមួយ សម្រាប់តភ្ជាប់សេវាកម្មអ៊ីនធើណេត ដើម្បីជៀសវាងផលប៉ះពាល់ដាច់សេវារបស់ខ្លួន ក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនេះ ព្រោះថានៅទី១៩ ខែមីនា ឆ្នាំ២០២១ តទៅ ចុងចម្លើយនឹងបញ្ឈប់ការផ្តល់សេវាបណ្តាញខ្សែកាបអុបទិកទាំងអស់តែម្តង។

### គ. សេចក្តីថ្លែងការណ៍របស់ភាគី

នាកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការបានឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុនៃការទាមទារ ក៏ដូចជាសេចក្តីថ្លែងការណ៍តប ដូចខាងក្រោមនេះ។

គ.១ សេចក្ដីថ្លែងការណ៍របស់ដើមចោទ

លោកមេធាវី [redacted] អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ដូចខាងក្រោមថា៖

ខ្ញុំបាទសូមរក្សាខ្លឹមសារ ដូចមានក្នុងពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ និងពាក្យស្នើសុំកែតម្រូវពាក្យបណ្ដឹង ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល។

គ.២ សេចក្ដីថ្លែងការណ៍តបរបស់ចុងចម្លើយ

ខ្ញុំបាទ មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានថ្លែងការណ៍ដូចខាងក្រោមថា៖

ទី១ ពាក់ព័ន្ធនឹងកម្មវត្ថុរបស់ដើមចោទ គឺជាបណ្ដឹងផ្ទុយនឹងច្បាប់ យោងតាមមាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ទី២ គឺវិវាទជាក់ស្ដែង ដែលអាចដោះស្រាយដោយសាលក្រមបាន។ ចំណុចនេះ គឺយើងមើលលើកម្មវត្ថុរបស់ដើមចោទ ដែលសុំឱ្យបន្តអនុវត្តកិច្ចសន្យាជួល។ ប៉ុន្តែ ដើមចោទបែរជាមិនអនុវត្តកាតព្វកិច្ចដោយខ្លួនឯងទៅវិញ ព្រោះថាដើមចោទមិនព្រមបង់ប្រាក់ ដែលជាបំណុលប្រើប្រាស់បណ្ដាញអុបទិចរបស់ចុងចម្លើយនោះឡើយ។ ដូច្នេះ ការប្ដឹងសុំសាលក្រមបង្គាប់ឱ្យចុងចម្លើយបន្តអនុវត្តកិច្ចសន្យា គឺជាការទាមទារមិនត្រឹមត្រូវស្របច្បាប់។ ចំពោះការទាមទារចំណុចទី២ របស់ដើមចោទ ដែលទាមទារសុំឱ្យចុងចម្លើយប្រគល់វិក័យបត្រពាក់ព័ន្ធនឹងបំណុល តែជាក់ស្ដែង **និយ័តករទូរគមនាគមន៍កម្ពុជា** បានអញ្ជើញទាំងដើមចោទ និងចុងចម្លើយមកផ្សះផ្សារសម្របសម្រួល ព្រមទាំងបង្ហាញវិក័យបត្រ និងចំនួនទឹកប្រាក់ដល់គូភាគី ហើយក៏បានឯកភាពកំណត់ ពេលវេលានៃការទូទាត់សងបំណុលដែរ។ ប៉ុន្តែ ដល់ពេលកំណត់ ដើមចោទមិនព្រមយកប្រាក់មកទូទាត់តាមការសម្របសម្រួលរបស់ **និយ័តករទូរគមនាគមន៍កម្ពុជា** ដដែល ទើបមានសេចក្ដីសម្រេចឱ្យក្រុមហ៊ុនផ្អាកការផ្ដល់ខ្សែកាប ទៅឱ្យក្រុមហ៊ុនរបស់ដើមចោទ ដោយទុករយៈពេលមួយខែ ដើម្បីឱ្យចុងចម្លើយជូនដំណឹងអតិថិជន ដែលកំពុងប្រើប្រាស់ខ្សែរកាបជាមួយនឹងក្រុមហ៊ុនរបស់ដើមចោទ ជ្រើសរើសក្រុមហ៊ុនថ្មី។ ក្រោយពេលទទួលបានសេចក្ដីសម្រេចរបស់ **និយ័តករទូរគមនាគមន៍កម្ពុជា** ចុងចម្លើយបានចាប់ផ្ដើមអនុវត្តគោលការណ៍ណែនាំនេះ ដោយធ្វើការជូនដំណឹងអតិថិជនទាំងអស់ ដែលប្រើប្រាស់អ៊ីនធើណេត ក្នុងរយៈពេល ៣០ថ្ងៃ មុននឹងធ្វើការផ្ដាច់ ឬ បញ្ឈប់ការផ្ដល់សេវាទាំងស្រុង។ ផ្ទុយទៅវិញ ដើមចោទបែរជាប្ដឹងសុំដីការក្សាការពារ ដោយហាមឃាត់ចុងចម្លើយមិនឱ្យបញ្ឈប់ ឬ ផ្អាកការផ្ដល់សេវាអ៊ិនធើណេតដល់អតិថិជនជាបណ្ដោះអាសន្ន។

នៅក្នុងនីតិវិធីនៃការអនុវត្តរក្សាការពារ ចៅក្រមអនុវត្ត បានកោះហៅភាគីដើម្បីធ្វើការសាកសួរ ដោយក្រុមហ៊ុនចុងចម្លើយ បានបញ្ជាក់ថា ខ្លួនមិនទាន់បានផ្ដាច់ ផ្អាកខ្សែរកាបអុបទិចនៅឡើយទេ។ ជាចុងក្រោយ ចៅក្រមអនុវត្ត បានសម្រេចលើកពាក្យស្នើសុំអនុវត្តដោយប្រយោលរបស់ដើមបណ្ដឹងចោល ហើយត្រូវបានដើមចោទប្ដឹងទាស់នឹងដីកាសម្រេចនេះទៅសាលាឧទ្ធរណ៍។ ជាចុងក្រោយ សាលាឧទ្ធរណ៍បានសម្រេចច្រានចោលពាក្យបណ្ដឹងជំទាស់របស់ដើមចោទ ដោយតម្កល់ដីកាសម្រេចរបស់សាលាដំបូងទុកជាបានការ។

បើពិនិត្យអំពីកម្មវត្ថុបណ្ដឹងអង្គសេចក្ដីរបស់ដើមចោទ ដោយយោងតាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការបានពិនិត្យឃើញថា មានចំណុចខ្វះខាត ដែលមានលក្ខណៈមិនស្របច្បាប់ ហើយបានចេញដីកាបង្គាប់ឱ្យដើមចោទធ្វើការកែតម្រូវបណ្ដឹងនេះ។ ប៉ុន្តែពាក្យសុំកែតម្រូវរបស់ដើមចោទ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ពុំមានខ្លឹមសារខុសពីបណ្ដឹងដើមនោះឡើយ។ ពាក់ព័ន្ធនឹងករណីនេះ តុលាការអាចពិចារណាលើកបណ្ដឹងចោល ស្របតាមបញ្ញត្តិមាត្រា ៧៨ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។ ចំណុចមួយទៀត ផ្អែកតាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការលើកចោលពាក្យបណ្ដឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ គឺមានមូលជាអាទិ៍៖ ទី១ បណ្ដឹងផ្ទុយច្បាប់



Scanned with CamScanner

ទី២ បណ្ដឹងរបស់ដើមចោទ ជាបណ្ដឹងដែលមានចំណុចខ្វះខាតដែលមិនអាចធ្វើការកែតម្រូវបាន និងចំណុចសំខាន់មួយទៀត គឺកម្មវត្ថុបណ្ដឹងគ្មានផលប្រយោជន៍គូភាគីដែល តុលាការអាចដោះស្រាយដោយចេញសាលក្រមបាន ព្រោះថាដើមចោទខ្លួនឯង ជាអ្នកបំពានកាតព្វកិច្ចនៃកិច្ចសន្យា។ ដូច្នេះ ក្នុងនាមខ្ញុំបាទអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ ស្នើសុំលោកចៅក្រមលើកបណ្ដឹងចោលដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។

គ.៣ សេចក្ដីថ្លែងការណ៍តបរបស់ដើមចោទ

លោកមេធាវី [redacted] បានធ្វើសេចក្ដីថ្លែងការណ៍តបដូចខាងក្រោមថា៖

ការលើកឡើងថា ដើមចោទមិនអនុវត្តកាតព្វកិច្ចនោះ គឺមិនត្រឹមត្រូវទេ ដោយហេតុថា ក្រុមហ៊ុនរបស់ចុងចម្លើយធ្លាប់ជំពាក់បំណុលក្រុមហ៊ុនរបស់ដើមចោទពាក់ព័ន្ធនឹងបញ្ហា Back Bone និង Metro Fibre ដែលចុងចម្លើយសន្យាថា ផ្ដល់ឱ្យក្រុមហ៊ុនកូនក្ដីខ្ញុំបាទ។ ក្រុមហ៊ុនរបស់ចុងចម្លើយ មិនទាន់បានសងបំណុលនោះមកឱ្យកូនក្ដីខ្ញុំបាទនៅឡើយទេ តែបែរជាដាក់ពាក្យបណ្ដឹងទាមទារឱ្យកូនក្ដីខ្ញុំបាទសងបំណុលទៅវិញ ដែលខុសពីកិច្ចប្រជុំពិភាក្សាគ្នាកាលពីដំបូង។ ជាក់ស្ដែង នៅក្នុងកំណត់ហេតុប្រជុំជាមួយនឹងនិយ័តករទូរគមនាគមន៍កម្ពុជា ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ បានបញ្ជាក់ និងទទួលស្គាល់ប្រាក់ដែលក្រុមហ៊ុន [redacted] ត្រូវទូទាត់ឱ្យក្រុមហ៊ុនស៊ីហ្វុក សម្រាប់ខែកក្កដា ខែសីហា ខែកញ្ញា និងខែតុលា ឆ្នាំ២០១៨ សរុបចំនួន ១២៤.៨៦៣,០៤ (ដប់ពីរម៉ឺនបួនពាន់ប្រាំបីរយហុកសិបបីដុល្លារអាមេរិក និងបួនសេន) ត្រូវបានក្រុមហ៊ុន [redacted] ទូទាត់បានចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក រួចហើយ តាមរយៈធនាគារ [redacted] ចំណែកទឹកប្រាក់ដែលសល់ក្រៅពីនេះត្រូវបាន និយ័តករទូរគមនាគមន៍កម្ពុជា ឱ្យក្រុមហ៊ុនទាំងពីរពិភាក្សាគ្នា ដោយរកលទ្ធភាពក្នុងការទូទាត់ តែមិនបានកំណត់អំពីកាលបរិច្ឆេទឡើយ។ម្យ៉ាងទៀត នៅក្នុងចំណុចទី៥ នៃកំណត់ហេតុប្រជុំដដែលនេះ និយ័តករទូរគមនាគមន៍កម្ពុជា បានកំណត់ថា ក្រុមហ៊ុនចុងចម្លើយ ត្រូវបន្តចេញវិក័យបត្រជូនក្រុមហ៊ុនដើមចោទដើម្បីអាចទូទាត់បំណុលបាន។ ប៉ុន្តែក្រោយពីការផ្សះផ្សារួចមក ក្រុមហ៊ុនចុងចម្លើយមិនដែលផ្ដល់ឱកាស ឬ លទ្ធភាពដើម្បីឱ្យក្រុមហ៊ុនដើមចោទធ្វើការទូទាត់សងបំណុលតាមស្មារតីនៃកិច្ចពិភាក្សាឡើយ។ ផ្ទុយទៅវិញ ក្រុមហ៊ុនចុងចម្លើយបានចេញសេចក្ដីជូនដំណឹងអំពីការផ្ដាច់ប្រព័ន្ធអ៊ីនធើណែតម្ដងជាពីរដង ដែលសេចក្ដីជូនដំណឹងចុងក្រោយ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ទាំងមិនទាន់បានបញ្ចប់ការដោះស្រាយដែលផ្ដល់ដោយ **និយ័តករទូរគមនាគមន៍កម្ពុជា** នោះឡើយ។ ក្រោយមកទៀត បន្ទាប់ពីកូនក្ដីខ្ញុំបាទបានទទួលសេចក្ដីជូនដំណឹងនោះ កូនក្ដីខ្ញុំបាន ផ្ញើលិខិតជូនដំណឹងលេខ ០៦៥/២០២១ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ ទៅឱ្យក្រុមហ៊ុនចុងចម្លើយ ដែលមានកម្មវត្ថុ ទី១ សុំឱ្យបន្តផ្ដល់សេវាកម្មលើបណ្ដាញអ៊ីនធើណែត និងទី២ សុំឱ្យក្រុមហ៊ុនចុងចម្លើយ បញ្ជាក់អំពីចំនួនបំណុលជាក់លាក់ រួមទាំងរបៀបនៃការទូទាត់ផងដែរ។ ការស្នើសុំបែបនេះ គឺដោយសារតែក្នុងសេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុនចុងចម្លើយ បានសរសេរថា ក្រុមហ៊ុនដើមចោទ បានជំពាក់បំណុលជាង **ពីរលានដុល្លារអាមេរិក** ដោយលើកឡើងនូវចំនួនទឹកប្រាក់នេះ ខុសពីចំនួនទឹកប្រាក់ដែលបានពិភាក្សាគ្នាក្នុងកំណត់ហេតុប្រជុំ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ហើយដែលក្រុមហ៊ុនចុងចម្លើយ មិនដែលបានផ្ញើរបាយការណ៍ ឬ វិក័យបត្រថ្លៃសេវាកម្ម មកឱ្យក្រុមហ៊ុនដើមចោទ ឱ្យបានដឹងមុននោះឡើយ។ យោងតាមអង្គហេតុខាងលើ និងភស្តុតាងដែលបានដាក់ចូលកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ អាចបញ្ជាក់បានថា មិនមែនជាចេតនារបស់ដើមចោទ ក្នុងការមិនទូទាត់ប្រាក់បំណុលដែលនៅសល់ជូនក្រុមហ៊ុនចុងចម្លើយទេ តែដោយសារចុងចម្លើយមិនអនុវត្តតាមការផ្សះផ្សារ ទើបធ្វើឱ្យដើមចោទដាក់ពាក្យបណ្ដឹងមកតុលាការ។ ដូច្នេះ កូនក្ដីខ្ញុំបាទនៅតែសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារនៃការទាមទារដដែល។

គ.៤ សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ

លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងតបបន្ថែមដូចខាងក្រោមថា៖

ចំពោះការលើកឡើងរបស់ដើមចោទនេះ ទី១ គឺផ្ទុយពីកម្មវត្ថុនៃបណ្តឹងទាំងស្រុង ព្រោះថាតាមពាក្យបណ្តឹងដើម និងពាក្យសុំកែតម្រូវពាក្យបណ្តឹង មិនមានខ្លឹមសារបញ្ជាក់ដូចការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ក្នុងពេលនេះឡើយ។ ទី២ ការលើកឡើងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ គឺបញ្ជាក់អំពីកាតព្វកិច្ចនៃកិច្ចព្រមព្រៀងសម្របសម្រួល ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់និយ័តករទូរគមនាគមន៍កម្ពុជាទាំងស្រុង។ ដូច្នេះ បង្ហាញឱ្យឃើញថា គឺត្រូវតែចូលមកទូទាត់បំណុលនៅ និយ័តករទូរគមនាគមន៍កម្ពុជា តាមខ្លឹមសារដែលបានលើកឡើង ដើម្បីបញ្ចប់បំណុលឱ្យជ្រះស្រលះ។ ចំណុចទី៣ ដើមចោទនៅតែអះអាងឱ្យចុងចម្លើយផ្តល់វិក័យបត្រទូទាត់ តែកិច្ចសន្យានេះត្រូវបានបង្កើត និងអនុវត្តចាប់តាំងពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០១៩ ទើបដើមចោទមានការមិនបំពេញកាតព្វកិច្ចក្នុងការទូទាត់បំណុល។ ដូច្នេះ បង្ហាញឱ្យឃើញថា រាល់ការទូទាត់បំណុលរវាងដើមចោទ និងចុងចម្លើយ គឺសុទ្ធតែអាចអនុវត្តតាមប្រព័ន្ធរដ្ឋបាលត្រឹមត្រូវ ដោយពុំបានលើកឡើងតាមផ្ទាល់មាត់ ឬ ក៏ទាមទារក្រៅពីឯកសារដែលភាគីបានព្រមព្រៀងគ្នានោះដែរ។ ទី៤ ការជូនដំណឹងពីការផ្អាកការផ្តល់សេវាអ៊ីនធើណែតជូនទៅអ្នកប្រើប្រាស់របស់ដើមចោទ ជាគោលការណ៍ និងនីតិវិធីរដ្ឋបាល ដែលចុងចម្លើយត្រូវរំលឹកដើមចោទដើម្បីឱ្យចូលមកទូទាត់បំណុល និងដាស់តឿនផងដែរ ប្រសិនបើមិនទូទាត់ យើងនឹងផ្អាកការផ្តល់សេវាបន្ត។ ទី៥ ការលើកឡើងរបស់ដើមចោទថា បានសុំបន្តកិច្ចសន្យា ហើយចុងចម្លើយបដិសេធនោះ គឺជាឆន្ទៈដែលបង្ហាញអំពីការមិនពេញចិត្តរបស់ចុងចម្លើយចំពោះដើមចោទដែលបានគេចវេះ មិនព្រមទូទាត់បំណុលតាមការព្រមព្រៀង។ ចំណុចទី៦ ដែលដើមចោទលើកឡើងថា បំណុលចុងក្រោយ ដែលចុងចម្លើយបានជូនដំណឹង មានលក្ខណៈកើនឡើងលើសពីបំណុលដែលបានព្រមព្រៀងគ្នា ដូចបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ នោះគឺជាការពិត ព្រោះថាដើមចោទនៅប្រើប្រាស់សេវាអ៊ីនធើណែតរបស់ចុងចម្លើយនៅឡើយ រហូតមកដល់ពេលនេះ ដោយមិនព្រមបង់ប្រាក់ទាល់តែសោះ។ ដូច្នេះ ខ្ញុំសំណូមពរ ប្រសិនបើដើមចោទចង់បន្តអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ត្រូវយកបំណុលមកទូទាត់ ឬ យកប្រាក់មកតម្កល់តាមចំនួនទឹកប្រាក់បំណុលនៅតុលាការ ដើម្បីបង្ហាញអំពីឆន្ទៈក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ១សប្តាហ៍ គិតចាប់ពីថ្ងៃនេះ។

គ.៥ សេចក្តីថ្លែងការណ៍តបរបស់ដើមចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបដូចខាងក្រោមថា៖

ទី១ ពាក់ព័ន្ធនឹងការជូនវិក័យបត្រលើការប្រើប្រាស់សេវាអ៊ីនធើណែតរបស់ចុងចម្លើយ ដែលមានទំហំជាង **ពីរលានដុល្លារអាមេរិក** កូនក្តីខ្ញុំបាទមិនដែលបានទទួលសោះឡើយ ហើយតាំងពីមានវិវាទ ចុងចម្លើយក៏មិនដែលបានបង្ហាញភស្តុតាងអំពីការបញ្ចប់ ឬ ការទទួលវិក័យបត្ររបស់ក្រុមហ៊ុនដើមចោទដែរ។ ចំណុចទី២ ការលើកឡើងថា សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុនចុងចម្លើយ ជាការដាស់តឿនរំលឹកឱ្យទូទាត់បំណុលនោះ ក៏មិនត្រឹមត្រូវដែរ ដោយហេតុថា ខ្លឹមសារនៃសេចក្តីជូនដំណឹង គឺសរសេរបញ្ជាក់អំពីការបញ្ឈប់ផ្តល់សេវាបណ្តាញខ្សែកាបអុបទិក ដល់អ្នកប្រើប្រាស់របស់ក្រុមហ៊ុនដើមចោទទាំងអស់ ហើយកូនក្តីខ្ញុំក៏មិនដែលបានទទួលលិខិតដាស់តឿនដែល។ តាមប្រការ ៤ ចំណុច ៤.២B បានកំណត់ថា ប្រសិនបើវិក័យបត្រ ត្រឹមត្រូវមិនត្រូវបានទទួលទេ អ្នកទទួលជួលនឹងមិនបង់ប្រាក់។ ដូច្នេះ ការមិនទូទាត់ប្រាក់បំណុលនេះ មិនមែនជាកំហុសរបស់កូនក្តីខ្ញុំឡើយ ហើយក៏មិនមែនជាហេតុ ផលស្របច្បាប់ក្នុងការកាត់ផ្តាច់ ឬលុបកិច្ចសន្យាក្របខណ្ឌនៃការជួលបណ្តាញតភ្ជាប់ខ្សែកាបអុបទិចដែរ។ ម្យ៉ាងទៀត ទោះបីជាមានការព្រមព្រៀងផ្សះផ្សាររបស់និយ័តករ ពាក់ព័ន្ធនឹងបំណុលដែលក្រុម

ហ៊ុនដើមចោទ ត្រូវទូទាត់ជូនក្រុមហ៊ុនចុងចម្លើយក៏ដោយ ក៏មិនមានន័យថា ក្រុមហ៊ុនចុងចម្លើយមានសិទ្ធិកាត់ផ្តាច់ប្រព័ន្ធអ៊ីនធើណែត ឬបញ្ចប់កិច្ចសន្យាក្របខណ្ឌ នៃការជួលបណ្តាញតភ្ជាប់ខ្សែកាបអុបទិចនោះដែរ។

គ.៦ សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ

លោកមេធាវី [redacted] បានសេចក្តីថ្លែងការណ៍តបបន្ថែមដូចខាងក្រោមថា៖

ទី១ ពាក្យថា កិច្ចសន្យាពាក់ព័ន្ធនឹងទឹកប្រាក់ គឺមានចែងក្នុងកិច្ចសន្យាស្របច្បាប់ ហើយចំនួនទឹកប្រាក់ដែលត្រូវបង់ គឺដើមចោទក៏បានដឹងអំពីចំនួនទឹកប្រាក់ដែលចុងចម្លើយបានជូនវិក័យបត្រជារៀងរាល់ខែ។ ទី២ ការជូនដំណឹងដាស់តឿន គឺដោយសារដើមចោទមិនបានអនុវត្តកាតព្វកិច្ចទូទាត់បំណុលតាមកិច្ចសន្យា ទើបចុងចម្លើយជូនដំណឹងរំលឹក។ ទី៣ ការបរិច្ឆេទនៃការសម្របសម្រួលរបស់នីយ័តកម្ម គឺជាការបង្ហាញនូវឆន្ទៈគេចវេះពីបំណុលរបស់ដើមចោទ។ ទី៤ ការលើកឡើងថាការជូនដំណឹងរបស់ចុងចម្លើយ ជាការជូនដំណឹងបញ្ចប់កិច្ចសន្យា គឺជាការភន្តច្រឡំទាំងស្រុង ព្រោះថាតាមច្បាប់ ការ បញ្ចប់កិច្ចសន្យា គឺ៖ ទី១ ដល់កំណត់អាជ្ញាយុការ ទី២ ការព្រមព្រៀងរបស់ភាគី ទី៣ ការផ្ទេរសិទ្ធិ និងកាតព្វកិច្ចទៅភាគីទី៣ ទី៤ សាលក្រម ឬសេចក្តីសម្រេចរបស់តុលាការ។ ដូច្នេះ ខ្ញុំនៅតែសំណូមពរទី១ ដើមចោទយកប្រាក់មកទូរទាត់តាមកិច្ចសន្យា ទី២ យកប្រាក់មកតម្កល់តាមចំនួននៃបំណុល ដោយហេតុថា កម្មវត្ថុនៃបណ្តឹងពុំមានផលប្រយោជន៍ ដែលគួរឱ្យ តុលាការដោះស្រាយចេញជាសាលក្រមបាន ក្នុងខ្លឹមសារនៃកម្មវត្ថុបណ្តឹងពុំអាចកំណត់អាត្រាពន្ធតាមផ្លូវច្បាប់បាន។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យចំពោះបណ្តឹង

ក.១ ផ្អែកតាមពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ របស់ដើមចោទជាក្រុមហ៊ុន [redacted] ដែលមានឈ្មោះ [redacted] HUA ជាអ្នកតំណាងដែលច្បាប់បានកំណត់ ដើមចោទបានដាក់ពាក្យបណ្តឹងទាមទារសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយអនុវត្តកិច្ចសន្យាស្តីពីការជួលបណ្តាញ [redacted] លេខ SINGMENG CFOCN 201607150 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦។ ក្រោយមកដើមចោទបានដាក់ពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ដែលមានខ្លឹមសារកែតម្រូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ មកជា ទាមទារសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយបន្តអនុវត្តកិច្ចសន្យាក្របខណ្ឌនៃការជួលបណ្តាញតភ្ជាប់ខ្សែកាបអុបទិក [redacted] លេខ SINGMENG CFOCN 201607150 រួមមានដូចជា៖ ការផ្តល់សេវាជួលបណ្តាញតភ្ជាប់ខ្សែកាបអុបទិក សេវាកម្មថែទាំ និងសេវាកម្មតភ្ជាប់ឡើងវិញ ជូនអតិថិជនដែលត្រូវបានកាត់ផ្តាច់កន្លងមក ដោយហាមមិនឱ្យចុងចម្លើយកាត់ផ្តាច់ ឬបញ្ឈប់ការផ្តល់សេវាជួលបណ្តាញរបស់ដើមចោទ លុះត្រាមានការរំលោយកិច្ចសន្យា ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាជួលបណ្តាញតភ្ជាប់ខ្សែកាបអុបទិក ឬក្នុងករណីដើមចោទមិនអនុវត្តតាមកាតព្វកិច្ចណាមួយ ដែលមានកំណត់ក្នុងកំណត់ហេតុផ្សះផ្សាវិវាទលើបញ្ហា [redacted] ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

ក.២ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍យ៉ាងច្បាស់ថា សេចក្តីជូនដំណឹង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចុងចម្លើយ ជូនដំណឹងឱ្យដើមចោទ គឺជាសេចក្តីជូនដំណឹងបញ្ជាក់អំពីការដាស់តឿន ដោយសុំឱ្យដើមចោទសងប្រាក់ជំពាក់មកខ្លួន មិនមែនជាការជូនដំណឹងស្តីពីការរំលោយកិច្ចសន្យានោះទេ។ ដូច្នេះ តុលាការពិនិត្យឃើញថា ចុងចម្លើយគ្មានចេតនាណាមួយ [illegible]

កិច្ចសន្យាស្តីពីការជួលបណ្តាញ [redacted] លេខ SINGMENG CFOCN 201607150 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ ឬ បានរំលាយរួចហើយនោះឡើយ។ ដូចនេះ ឃើញថា ការទាមទាររបស់ដើមចោទ ដែលទាមទារសុំឱ្យបន្តកិច្ចសន្យាខាងលើនេះ គ្មានផលប្រយោជន៍តាមផ្លូវបណ្តឹងនោះឡើយ។ ដូច្នេះ គប្បីតុលាការ លើកបណ្តឹងចោល ស្របតាមបញ្ញត្តិមាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ. បន្ទុកនៃប្រាក់ប្រដាប់ក្តី**

ដោយតុលាការលើកចោលបណ្តឹងរបស់ដើមចោទនេះ។ ដូច្នេះ ដើមចោទត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី ស្របតាម បញ្ញត្តិមាត្រា ៦៤ នៃក្រមរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១. លើកចោលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។

២. ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះបានប្រកាសជាសាធារណៈ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។ ក្នុងករណីដែលត្រូវប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើង ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។

ថ្ងៃសុក្រ ១០ កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២

ហត្ថលេខា និងត្រា៖ [redacted]

---

**បានឃើញ**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១០ កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]